## រឿងទី៦៖ ឈើឆ្កាង

**ខគម្ពីរ៖ លូកា២៤:៧**

«បុត្រមនុស្ស នឹងត្រូវគេបញ្ជូនទៅក្នុងកណ្ដាប់ដៃរបស់មនុស្សបាប គេនឹងឆ្កាងព្រះអង្គ តែបីថ្ងៃក្រោយមក ព្រះអង្គមានព្រះជន្មរស់ឡើងវិញ»។

មានថ្ងៃមួយ ព្រះយេស៊ូបាននាំពួកសាវកទាំងអស់ឡើងទៅលើភ្នំគេតសេម៉ានី។ ព្រះយេស៊ូបានឱនក្រាបអធិស្ឋានទូលអង្វរនៅចំពោះព្រះជាម្ចាស់។

ពេលព្រះយេស៊ូកំពុងតែអធិស្ឋាន មានពួកទេវតាចុះពីលើមេឃ មកធ្វើជាកម្លាំងដល់ព្រះយេស៊ូ។

បន្តិចក្រោយមក ស្រាប់តែយូដាសជាសាវកម្នាក់ក្នុងចំណោមសាវកទាំងដប់ពីរបានមកជាមួយពួកទាហានមានកាន់ដាវ និងដំបងគ្រប់គ្នា។

យូដាសបានទៅរកក្រុមនាយកបូជាចារ្យ ដែលជាអ្នកដឹកនាំក្នុងក្រុងយេរូសាឡឹម ហើយបានលក់ព្រះយេស៊ូទៅឱ្យពួកគេក្នុងតម្លៃសាមសិបស្លឹង។

យូដាសបាននិយាយទៅពួកទាហានថា៖ «បើខ្ញុំថើបអ្នកណា ចូរចាប់អ្នកនោះចុះ ដ្បិតអ្នកនោះហើយជាព្រះយេស៊ូ»

យូដាសបានដើរទៅជិតព្រះយេស៊ូ ហើយថើបទ្រង់។ ភ្លាមនោះ ពួកទាហាន ក៏សម្រុកមកចាប់ព្រះយេស៊ូ។

ពួកទាហានបាននាំយកព្រះយេស៊ូទៅឱ្យមហាបូជាចារ្យកាត់ទោស។ មហាបូជាចារ្យ និងអ្នកដឹកនាំប្រជាពលរដ្ឋទាំងអស់ បានសម្រេចថានឹងកាត់ទោសប្រហារជីវិតព្រះយេស៊ូ។

បណ្ដាជនទាំងអស់ បានស្ដោះទឹកមាត់ដាក់ព្រះយេស៊ូ ហើយបានវាយព្រះយេស៊ូ។

នៅព្រឹកថ្ងៃបន្ទាប់ មនុស្សម្នា បាននាំយកព្រះយេស៊ូទៅលោកពីឡាតជាទេសាភិបាល។

មហាបូជាចារ្យ និងអ្នកដឹកនាំទាំងអស់បាននិយាយមិនល្អពីព្រះយេស៊ូនៅចំពោះមុខលោកពីឡាត។ ប៉ុន្តែ ទោះពួកគេនិយាយអ្វីក៏ដោយ ព្រះយេស៊ូនៅស្ងៀមមិនមានបន្ទូលអ្វីទាំងអស់។ លោកពីឡាតបានដឹងថា ព្រះយេស៊ូគ្មានទោសសោះ។

នៅសម័យនោះ គេមានទម្លាប់ដោះលែងអ្នកទោសម្នាក់នៅក្នុងពិធីបុណ្យចម្លង។

ដូច្នេះ លោកពីឡាតបាននិយាយទៅកាន់ពួកមហាជនថា៖ «តើអ្នករាល់គ្នាចង់ឱ្យខ្ញុំដោះលែងអ្នកទោសមួយណា? បារ៉ាបាស ឬយេស៊ូនេះ?

មហាជនទាំងអស់ បានសុំឱ្យលោកដោះលែងបារ៉ាបាស។ បារ៉ាបាសជាអ្នកទោសម្នាក់ដែលជាប់គុកដោយសារបានសម្លាប់មនុស្ស។

ពួកបណ្ដាជនទាំងឡាយបានគម្លើងសម្លេងឡើង ធ្វើឱ្យលោកពីឡាតភិតភ័យ។

ចុងក្រោយ លោកពីឡាតក៏សម្រេចចិត្តដោះលែងបារ៉ាបាស ហើយឱ្យគេវាយព្រះយេស៊ូនឹងរំពាត់ រួចបញ្ជូនទ្រង់ឱ្យទៅឆ្កាង។



ពួកទាហានបានយកអាវពណ៌ក្រហមទុំ មកពាក់ឱ្យព្រះយេស៊ូ រួចយកមកុដដែលខ្លួនបានក្រងពីបន្លាមកបំពាក់លើព្រះសិរសាព្រះអង្គ ហើយឱ្យទ្រង់កាន់ដំបងនៅនឹងដៃ ហើយពួកទាហានធ្វើជាលុតជង្គង់ថ្វាយបង្គំ ប្រមាថមើលងាយព្រះអង្គ។

ពួកទាហានដោះអាវពណ៌ក្រហមទុំនោះចេញ ហើយបំពាក់អាវរបស់ទ្រង់វិញ រួចបញ្ជូនទ្រង់ទៅឆ្កាង។

ព្រះយេស៊ូបានលីឈើឆ្កាងរបស់ទ្រង់យាងឡើងទៅលើភ្នំគាល់កូថា ប៉ុន្តែ ដោយសារឈើឆ្កាងធ្ងន់ខ្លាំង ធ្វើឱ្យព្រះយេស៊ូទ្រាំលែងបានក៏ដួល។

ពួកទាហានបានបង្ខំបុរសម្នាក់ឈ្មោះស៊ីម៉ូនដែលដើរឆ្លងកាត់ទីនោះ ឱ្យជួយលីឈើឆ្កាងរបស់ព្រះយេស៊ូបន្ត។

ទីបំផុត ព្រះយេស៊ូក៏យាងទៅដល់ភ្នំគាល់កូថា។ ពួកទាហាន បានដោះសម្លៀកបំពាក់ចេញពីព្រះយេស៊ូ។

ហើយបានដំដែកគោលធំៗនៅលើដៃ និងជើង រួចព្យួរទ្រង់នៅលើឈើឆ្កាង។ ពួកទាហាន បានយកសម្លៀកបំពាក់ព្រះយេស៊ូមកចាប់ឆ្នោតចែកគ្នា។

ពួកគេបានសរសេរពាក្យថា «ស្ដេចជនជាតិយូដា» នៅពីលើឈើឆ្កាងរបស់ព្រះយេស៊ូ។

ព្រះយេស៊ូទ្រង់អត់ទ្រាំនឹងការឈឺចាប់នោះ ហើយមានបន្ទូលថា៖ «បិតាអើយ សូមអត់ទោសដល់ពួកគេផង ដ្បិតពួកគេមិនបានដឹងថាពួកគេកំពុងធ្វើអ្វីទេ»។ បន្តិចក្រោយមក ផែនដីក៏ប្រែជាងងឹតសូន្យសុង។

វេលានោះ ព្រះយេស៊ូបន្លឺសម្លេងយ៉ាងខ្លាំងដូចនេះថា៖ «ឱព្រះនៃទូលបង្គំអើយ ព្រះនៃទូលបង្គំអើយ ហេតុអ្វីបានជាព្រះអង្គបោះបង់ទូលបង្គំចោលដូច្នេះ?»។ ព្រះយេស៊ូបានជ្រាបថា ទ្រង់បានបញ្ចប់កិច្ចការដែលទ្រង់ត្រូវធ្វើនៅផែនដីនេះរួចអស់ហើយ។

ដូច្នេះ ទ្រង់បន្លឺព្រះសូរសៀងតិចៗថា៖ «ខ្ញុំបានសម្រេចសព្វគ្រប់អស់ហើយ!»

មានបន្ទូលរួច ព្រះយេស៊ូក៏ផុតវិញ្ញាណទៅ។ ភ្លាមនោះ ស្រាប់តែវាំងននទៅក្នុងព្រះវិហារ បានរហែកជាពីរ តាំងពីលើដល់ក្រោម។

នៅលើភ្នំគាល់កូថា ក៏មានរញ្ជួយដីយ៉ាងខ្លាំង ថ្មផ្ទុះប្រះបែកចេញពីគ្នា។ បុត្រារបស់ព្រះជាម្ចាស់ទ្រង់បានសុគតជំនួសអំពើបាបរបស់មនុស្សគ្រប់គ្នា។

- សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញឱ្យចាំ(លូកា២៤:៧)

បុត្រមនុស្ស*នឹងត្រូវគេបញ្ជូនទៅក្នុងកណ្ដាប់ដៃរបស់មនុស្សបាប គេនឹងឆ្កាងព្រះអង្គ



## សកម្មភាពទី១

សូមបត់ឈើឆ្កាងដែលព្រះយេស៊ូបានលី ដើម្បីយើងរាល់គ្នា រួចចំណាយពេលអរព្រះគុណដល់ក្ដីស្រឡាញ់របស់ព្រះយេស៊ូ។

**សម្ភារៈ៖ កន្ត្រៃ កាវ**

១. សូមកាត់ក្រដាសពណ៌ក្រហមខាងក្រោម



២. សូមធ្វើតាមលំដាប់លំដោយខាងក្រោម ដើម្បីបង្កើតចេញជាឈើឆ្កាង។



បន្ទាប់មក សូមលាក្រដាស។

៣. សូមកាត់រូបភាពខាងក្រោម រួចយកឈើឆ្កាងដែលបានធ្វើរួចនោះទៅបិទពីលើ។



រូបភាពរួចរាល់

